ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី
អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល
លេខៈ ០៥១/២១ អអរ

## សេចក្ដីប្រកាសព័ត៌មាន
## ស្ដីពីលទ្ធផលនៃសន្និសីទសារព័ត៌មាន ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១

ព្រឹកថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្ដីពី **«វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និងទិសដៅការងារបន្តរបស់ខេត្តកែប»** ដែលមានវាគ្មិនចូលរួមគឺ៖

- **ឯកឧត្ដម សំ សារីន ប្រធានក្រុមប្រឹក្សាខេត្តកែប**
- **លោក ទៅ សុខា អភិបាលរង នៃគណៈអភិបាលខេត្តកែប**
- **លោក ម៉ម ឡូច ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត**
- **លោក ចឹង បូរិន ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត**
- **លោកស្រី គឹម ចន្ធី អភិបាលស្រុកដំណាក់ចង្អើរ**
- **លោក លី ហ៊ាត មេឃុំពងទឹក ស្រុកដំណាក់ចង្អើរ**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងបង្ហាញសាធារណជនឱ្យបានយល់ច្បាស់ពីយន្តការប្រជាធិបតេយ្យថ្នាក់ក្រោមជាតិជាប្រវត្តិសាស្ត្រកម្ពុជា និងផ្សព្វផ្សាយពីសមិទ្ធផល ដែលរដ្ឋបាលថ្នាក់មូលដ្ឋានខិតខំប្រឹងប្រែងបំពេញការងារសម្រេចបាន ក្នុងការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍន៍មូលដ្ឋានឃុំ-សង្កាត់។

### I. សេចក្ដីផ្ដើម

ខេត្តកែប គឺជាខេត្តមួយដែលមានទំហំផ្ទៃដីគោកសរុប ១៨៧,២៤គ.ម² ព្រមទាំងមានផ្ទៃសមុទ្រ និងមានកោះចំនួន១២ ថ្មផុះស្ងួត ០១កន្លែង និងថ្មប៉ប្រះទឹក ០១កន្លែង ដោយសក្ដានុពលសេដ្ឋកិច្ចរបស់ខេត្តពឹងផ្អែកលើវិស័យទេសចរណ៍ កសិកម្ម កសិឧស្សាហកម្ម ស្រែអំបិល និងនេសាទ

ដែលមានផ្ទៃខ្សាច់ ឧទ្យានជាតិ ព្រៃកោងកាង ផ្កាថ្ម ស្មៅសមុទ្រ និងជីវៈចម្រុះ រួមទាំងធនធានជលផល សមុទ្រជាច្រើនប្រភេទផ្សេងទៀត។

## II. វឌ្ឍនភាពការងារ

វឌ្ឍនភាពការងារដែលខេត្តសម្រេចបានរួមមាន៖

❖ **ក្រុមប្រឹក្សាខេត្ត**

- ការងារកសិកម្ម៖ មានផ្ទៃដីស្រូវវង្វេរវស្សាចំនួន ៣.៥៤៣ហ.ត ក្នុងនោះស្រូវស្រាលចំនួន ១.០៥០ហ.ត ស្រូវកណ្តាល ១.២៥៩ហ.ត និងស្រូវធ្ងន់ ១.១០២ហ.ត, ដំណាំបន្លែបាន ចំនួន ៤៥៨ហិកតា ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មរយៈពេលខ្លីសរុបរួមចំនួន ១.២៨១ ហិកតា ស្វាយ ខ្នុរ ធុរេន ក្រូច ក្រូចថ្លុង ដូងធម្មតា ដូងក្រអូប ស្វាយចន្ទី ល្មុត ទៀប ស្រកានាគ បិរ និងម្រេចសរុបចំនួន ១.៣៧០,៤៦ហ.ត និងមានសហគមន៍នេសាទមាន ៥ សហគមន៍ ដោយអនុវត្តនផ្ទៃដីសរុប ៣.០៣១ហិកតា។
- ការងារទេសចរណ៍៖ មានកោះចំនួន១២ ថ្មផុះស្ទួត ០១កន្លែង និងថ្មប៉ប្រះទឹក ០១កន្លែង ព្រៃ កោងកាងចំនួន៣ កន្លែង មានផ្ទៃក្រឡា ១.០០៥ហិកតា ស្មៅសមុទ្រ ៣០៩៥ហិកតា ផ្កាថ្ម ៥២,៥ហិកតា និងមានធនធានធម្មជាតិមានត្រីផ្សោត ជ្រូកទឹក អណ្តើកសមុទ្រ ត្រីសេះ ក្តាម សេះដែលមានសេជាតិឆ្ងាញ់ ក្តាមថ្ម និងឧទ្យានជាតិកែបមានទំហំ ១.១៥២ហិកតា។ ក្នុងនោះ ភ្ញៀវទេសចរសរុបចំនួន ១.៣៩៦.១២៥នាក់ បើធៀបឆ្នាំ២០១៩ ចំនួន ១.៧៤៧.៦២២នាក់ ថយចុះ ២០,១១% ភ្ញៀវទេសចរជាតិចំនួន ១.៣៦៥.៦២២នាក់ បើធៀបឆ្នាំ២០១៩ចំនួន ១.៦៨៣.០០៩នាក់ ថយចុះ ១៨,៨៦% ភ្ញៀវទេសចរអន្តរជាតិចំនួន ៣០.៥០៣នាក់ បើធៀប ឆ្នាំ២០១៩ចំនួន ៦៤.៦១៣នាក់ ថយចុះ ៥២,៧៩%។
- ការងារប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ ១៩៖ បានចូលរួមផ្សព្វផ្សាយ និងអប់រំប្រជាពលរដ្ឋនៅ មូលដ្ឋានតាមសារអប់រំណែនាំរបស់ក្រសួងសុខាភិបាលជាប្រចាំ និងបានឧបត្ថម្ភថវិកា គ្រឿង ឧបភោគ បរិភោគដល់ប្រជាពលរដ្ឋ ដែលរងផលប៉ះពាល់ពីជំងឺនេះទូទាំងខេត្ត ព្រមទាំងបាន បានចូលរួមបរិច្ចាគថវិកាដើម្បីទិញវ៉ាក់សាំងប្រឆាំងមេរោគកូវីដ-១៩ មានទឹកប្រាក់សរុប ចំនួន ៣១.២០៦.០០០រៀល និង ១២.២២៦,១១ដុល្លាអាមេរិក។
- ការងារសេវាសាធារណៈ៖ បានត្រួតពិនិត្យការផ្តល់សេវាជូនប្រជាពលរដ្ឋនៅអង្គភាពច្រកចេញ ចូលតែមួយរដ្ឋបាលខេត្ត ដែលមានចំនួន១៤វិស័យ និងនៅការិយាល័យច្រកចេញចូលតែមួយ រដ្ឋបាលក្រុង១៤វិស័យ រដ្ឋបាលស្រុក ១៤វិស័យ បានផ្តល់សេវាជូនប្រជាពលរដ្ឋសរុបចំនួន ១៤.៧០៥សេវា។

❖ **ឃុំពងទឹក នៃស្រុកដំណាក់ចង្អើរ**

- ផ្នែកហេដ្ឋារចនាសម្ព័ន្ធ៖ មានទំនប់ ០៩កន្លែង ប្រឡាយទឹកមេ ១២ខ្សែ និងប្រឡាយរង៨ខ្សែ ស្រះទឹកមានចំនួន ១១៧ស្រះ និងអណ្តូងទឹកមានចំនួន ៦៩អណ្តូង, ផ្លូវក្រាលកៅស៊ូចំនួន០៤ខ្សែ ដែលមានប្រវែងសរុប ៧,៦១២ម៉ែត្រ ផ្លូវបេតុងចំនួន ០១ខ្សែ ប្រវែង ៩៨០ម៉ែត្រ និងផ្លូវលំក្រាលក្រួសក្រហម ២៦ខ្សែ មានប្រវែងសរុប ៦៥,១៣០ ម៉ែត្រ, ផ្សារមានចំនួន ០២កន្លែង, មតេយ្យសហគមន៍ ០២កន្លែង សាលាកាសាចិន ០១កន្លែង សាលាបឋមសិក្សាមានចំនួន ០៧កន្លែង អនុវិទ្យាល័យ ០២កន្លែង និងវិទ្យាល័យ ០១កន្លែង, មានមណ្ឌលសុខភាពចំនួន ០២កន្លែង និងវត្តអារាមព្រះពុទ្ធសាសនាមាន ៥កន្លែង។
- ការងារសេវាសាធារណៈ៖ បានបំរើសេវាសាធារណៈជូនប្រជាពលរដ្ឋដោយអនុវត្តគម្រោងច្រកចេញ-ចូលតែមួយអត្តសញ្ញាណកម្ម ប្រើប្រព័ន្ធបច្ចេកវិទ្យាអនឡាញសម្រាប់បញ្ចូលទិន្នន័យ ដែលជាហេតុធ្វើឱ្យការងារផ្តល់សេវាមានភាពលឿនហើសទាន់ចិត្ត។
- ការងារប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩៖ បានចុះតាមខ្នងផ្ទះដោយបានចែកម៉ាស់ អាល់កុលស្បៀង និងបានចែកខិតប័ណ្ណអប់រំប្រយុទ្ធប្រឆាំងការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ព្រមទាំងបានផ្សព្វផ្សាយ និងជំរុញដល់ប្រជាពលរដ្ឋ បង្កើនការដាំដុះ បន្លែ ផ្លែឈើ ការចិញ្ចឹមសត្វ ចិញ្ចឹមត្រី កង្កែប ក្នុងនោះក៏មានគម្រោង អាស់ស្សាំយ ចងក្រងជាបណ្តុំដាំបន្លែគ្រប់មុខ ដាំស្វាយ ដាំពោត ចិញ្ចឹមមាន់ ចិញ្ចឹមត្រី ចិញ្ចឹមកង្កែប និងដាំទំពាំងផ្អែម បានចំនួន ៧បណ្តុំ ស្មើនឹង ១១ក្រុម មានមនុស្សសរុប ៥២៤នាក់ ដោយមានអាជីវករចូលទិញដល់កន្លែងតាមតម្លៃទីផ្សារសេរី។
- ការងារសន្តិសុខ និងសណ្តាប់ធ្នាប់៖ បានអនុវត្តគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព ដោយបានរៀបចំធ្វើវេទិកាសាធារណៈស្តីពីតម្រូវការ និងសំណូមពររបស់ប្រជាពលរដ្ឋ។

## III. ទិសដៅការងារបន្ត

❖ **ក្រុមប្រឹក្សាខេត្ត**

- បន្តជ្រោមជ្រែង និងផ្តល់យោបល់ជូនគណៈអភិបាលខេត្តក្នុងការជួយធ្វើឱ្យមានកំណើនសេដ្ឋកិច្ចក្នុងខេត្ត
- ជំរុញការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងជាចំដោយដុំដើម្បីធានានូវការគ្រប់គ្រងប្រើប្រាស់ដីធ្លីប្រកបដោយប្រសិទ្ធភាព ចូលរួមទប់ស្កាត់បញ្ហាទំនាស់ដីធ្លី

- បន្តចូលរួមអប់រំ ណែនាំប្រជាពលរដ្ឋ អំពីការអនុវត្តដោយប្រុងប្រយ័ត្ននូវវិធានការការពារ និងទប់ស្កាត់ ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- ជំរុញការផ្តល់សេវាសាធារណៈ និងសេវារដ្ឋបាលជូនប្រជាពលរដ្ឋឱ្យបានទាន់ពេលវេលា ប្រកប ដោយប្រសិទ្ធភាព តាមរយៈការអនុវត្តក្របខណ្ឌការងារគណនេយ្យភាព សង្គម និងយន្តការច្រកចេញចូលតែមួយ ដើម្បីបង្វិតសេវាសាធារណៈឱ្យកៀក និងប្រជាពលរដ្ឋ មូលដ្ឋាន ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព
- បន្តពង្រឹងគោលនយោបាយរៀបចំផែនការអភិវឌ្ឍន៍ និងការកសាងកម្មវិធីវិនិយោគខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ ឱ្យមានសង្គតិភាព និងការរៀបចំយុទ្ធសាស្ត្រថវិកា ឱ្យសម ស្របទៅតម្រូវការក្នុងការអភិវឌ្ឍន៍
- ពង្រឹងទំនាក់ទំនងរវាងក្រុមប្រឹក្សា និងគណៈអភិបាល និងគាំទ្រក្នុងការកៀគធនធាន ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចក្នុងមូលដ្ឋាន។

❖ **ឃុំពងទឹក នៃស្រុកដំណាក់ចង្អើរ**

- ផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋចូលរួមចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ
- ជំរុញការផ្តល់សេវាសាធារណៈ និងសេវារដ្ឋបាលជូនប្រជាពលរដ្ឋឱ្យបានទាន់ពេលវេលា ប្រកប ដោយប្រសិទ្ធភាព
- បន្តដោះស្រាយរាល់សំណើ សំណូមពររបស់ប្រជាពលរដ្ឋ ដែលនៅសេសសល់គ្រប់ មូលដ្ឋាន
- បន្តអនុវត្តយន្តការសម្រុះសម្រួល និងដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
- ផ្សព្វផ្សាយ និងផ្តល់ឱកាសដល់ប្រជាពលរដ្ឋយល់ដឹងអំពីច្បាប់ សារាចរណ៍ណែនាំ និង គោលការណ៍នានា
- បន្តចូលរួមក្នុងការប្រយុទ្ធប្រឆាំងការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ដោយបានចូលរួម ផ្សព្វផ្សាយ អប់រំណែនាំប្រជាពលរដ្ឋនៅមូលដ្ឋាន តាមសារអប់រំណែនាំរបស់ក្រសួង សុខាភិបាល
- បន្តធ្វើវេទិកាសាធារណៈនៅតាមភូមិដើម្បីក្តាប់បានបញ្ហា សំណូមពរ និងរក ដំណោះស្រាយជូន ប្រជាពលរដ្ឋ
- ជំរុញការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព និងស្វែងរកទីផ្សារជូន ប្រជាពលរដ្ឋ។

## IV. សម្គាល់

- ដោយកំពង់ផែខេត្តកែបជាផែទឹករាក់ ដូចនេះការនេសាទខុសច្បាប់មានលក្ខណៈជាទ្រង់ទ្រាយធំពុំមានលក្ខណៈគួរកត់សម្គាល់នោះទេ ប៉ុន្តែការធ្វើនេសាទដោយខុសច្បាប់ជាលក្ខណៈគ្រួសារនៅតែបន្តកើតមានឡើង ខណៈដែលអាជ្ញាធរបានសហការជាមួយនគរបាលព្រំដែន និងអង្គការអភិរក្សសមុទ្រក្នុងការទប់ស្កាត់ និងបង្ក្រាបបទល្មើសនេះ។

- កំពង់ផែកោះទន្សាយ ជាផែទេសចរណ៍មួយ ដែលមានទំហំការងារ ៣ ៤៧០ម៉ែត្រការេ។ កំពង់ផែនេះ ចាប់ផ្តើមកសាងនៅដើមឆ្នាំ២០២០ និងត្រូវបានពន្យារពេលសាងសង់ដោយសារបញ្ហាកូវីដ១៩ និងបញ្ហាបច្ចេកទេស ប៉ុន្តែគម្រោងនៃការសាងសង់នេះនឹងត្រូវបញ្ចប់នាចុងខែសីហា ឆ្នាំ២០២១នេះ។ ដោយសារកត្តាផ្ទៃទឹកនៃកំពង់ផែមានជម្រៅចាប់ពី ៣ទៅ ៤,៧០ម៉ែត្រ ដូចនេះកំពង់ផែនឹងអនុញ្ញាតឱ្យនាវា ២ប្រភេទចូលចត ដែលនាវាប្រភេទទី១ អាចផ្ទុកមនុស្សបានចំនួន ៣០ ទៅ១០០នាក់ និងនាវាប្រភេទទី២ អាចផ្ទុកមនុស្សបាន ១០០ ទៅ៣០០នាក់៕

ថ្ងៃអង្គារ ៥រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១